Health
Centre for
Oral Health Strategy

# សន្លឹកពត៌មានអំពីធ្មេញ

Khmer / Dental Checks / April 2011

## ការឆែកពិនិត្យធ្មេញ

### តើ “ការបើកលើកបបូរមាត់” ជាអ្វី?

- “ការបើកលើកបបូរមាត់” គឺជាបច្ចេកទេសមួយដែលគេប្រើយ៉ាងទៀងទាត់ សំរាប់ឆែករកមើលសញ្ញានៃដង្កូវស៊ីធ្មេញក្នុងចំណោមកុមារ។
- នេះគឺជាការបើកលើកបបូរមាត់របស់កូនក្មេងតាមបែបសាមញ្ញប៉ុណ្ណោះ ដើម្បីរកមើលឲ្យឃើញនូវបញ្ហាដែលអាចកើតមានណាមួយ។

### តើពេលណាខ្ញុំគួរបើកលើកបបូរមាត់?

- ការឆែកពិនិត្យមើលមាត់ត្រូវបានណែនាំឲ្យធ្វើ ក្នុងអម្លុងពេលឆែកពិនិត្យសុខភាពកុមារ នៅពេលមានអាយុ៦-៨ខែ ១២ខែ ១៨ខែ ហើយនិង២ឆ្នាំ ៣ឆ្នាំ និង៤ឆ្នាំ។ (សូមយោងទៅ កំណត់ត្រាសុខភាពទីមួយរបស់ខ្ញុំ ៉សៀវភៅពណ៌ខៀវ ៉My First Health Record ‘blue book’ http://www.health.nsw.gov.au/pubs/2008/pdf/child_personal_health_record_1-40.pdf )
- មាតា ឬបិតា /អ្នកមើលថែ គួរចាប់ផ្តើមឆែកពិនិត្យមើលធ្មេញកូនរបស់គេឲ្យបានភ្លាម នៅពេលធ្មេញលេចឡើងក្នុងអាយុប្រហែល៦ខែ។
- ប្រសិនបើអ្នកសង្កេតឃើញមានស្នាមខ្មៅ ឬសអុច។ អ្នកគួរនាំកូនរបស់អ្នកទៅឲ្យអ្នកវិជ្ជាជីវៈខាងធ្មេញឆែកមើលធ្មេញ។

## ការទៅពិនិត្យមើលធ្មេញលើកទីមួយ

### តើពេលណាកូនរបស់ខ្ញុំគួរទៅពិនិត្យមើលធ្មេញលើកទីមួយ?

- កុមារទាំងអស់គួរឲ្យគេឆែកពិនិត្យធ្មេញរបស់ខ្លួននៅគ្រប់ពេលទៅពិនិត្យមើលសុខភាពកុមារ។ (សូមយោងទៅ កំណត់ត្រាសុខភាពទីមួយរបស់ខ្ញុំ ៉សៀវភៅពណ៌ខៀវ ៉My First Health Record ‘blue book’)
- កុមារទាំងអស់គួរឲ្យអ្នកវិជ្ជាជីវៈខាងធ្មេញវាយតម្លៃធ្មេញ ឲ្យបានទាន់ចុងអាយុឆ្នាំទី២របស់គេ។

### សេវាអ្នកបកប្រែភាសា

ប្រសិនបើអ្នកតម្រូវអ្នកបកប្រែភាសា ដើម្បីទាក់ទងជាមួយសេវាទាំងឡាយខាងលើនេះ ឬសេចក្តីបកប្រែណាមួយ សូមទូរស័ព្ទសេវាបកប្រែអត្ថបទ និងនិយាយ (TIS) តាមទូរស័ព្ទលេខ 13 14 50។

សំរាប់ពត៌មានផ្នែកសុខភាពពហុភាសាឯទៀត សូមបើកមើលវិបសាយ www.mhcs.health.nsw.gov.au